## ករណីសិក្សា

# ឥទ្ធិពលពីរបរស៊ីឈ្នួលបាញ់ថ្នាំកសិកម្ម

ស្រុកពាមជរ ស្រុកព្រះស្តេច ស្រុកស្វាយអន្ទរ និងស្រុកព្រៃវែង ជាស្រុកដែលមានផ្ទៃដីដាំដុះ ច្រើនជាងគេក្នុងចំណោមស្រុកទាំង ១២ របស់ខេត្តព្រៃវែង។ ដើម្បីរកប្រាក់កំរៃផ្គត់ផ្គង់ជីវភាព គ្រួសារកសិករក្រីក្រភាគច្រើនដែលរស់នៅក្នុងស្រុកទាំង៤ បានសំរេចចិត្តទៅស៊ីឈ្នួលបាញ់ថ្នាំកសិកម្ម។ ប្រាក់កំរៃទទួលបានពីរបរស៊ីឈ្នួលបាញ់ថ្នាំកសិកម្មគឺ១០,០០០រៀល (មួយម៉ឺនរៀលគត់) ក្នុងមួយថ្ងៃ ដោយពុំមានបន្ថែមសំភារៈអ្វីផ្សេងទៀត។ កសិករមិនហ៊ានចំណាយថវិកាទិញឧបករណ៍ការពារខ្លួនទេ ភាគច្រើនពួកគេធ្វើការមួយថ្ងៃ ដើម្បីផ្គត់ផ្គង់ជីវភាពមួយថ្ងៃ។ ម្ចាស់ស្រែមិនបានយកចិត្តទុកដាក់ចំពោះសុខភាពកសិករ ស៊ីឈ្នួលនោះ ទេ គឺគិតតែពីការងាររួចរាល់តាមពេលវេលា ដែលបានសន្យារវាងម្ចាស់ស្រែ និងកសិករស៊ីឈ្នួល។



បងស្រី **យ៉េត ឡុង** អាយុ២៨ឆ្នាំ ប្តីគាត់ឈ្មោះ **ភុយ ពាភ** ជាកសិករអាយុ ៣០ឆ្នាំ (ស្លាប់)**ម** បងស្រី មានកូន ០៣ នាក់ ស្រី១ ប្រុស២ រស់នៅភូមិពានរោង ឃុំទឹកថ្លា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ ប្តីបងស្រី ជាកសិករម្នាក់ក្នុងចំណោមកសិករដទៃទៀត ដែលបានទៅស៊ីឈ្នួលបាញ់ថ្នាំកសិកម្មលើដំណាំស្រូវប្រាំងនៅឃុំបារាយ ស្រុកព្រៃវែង។ ប្តីបងស្រី បានស្លាប់បាត់បង់ជីវិតដោយឥទ្ធិពលនៃថ្នាំកសិកម្ម រយៈពេល០២ខែកន្លងមកហើយ។ គ្រួសាររបស់បងស្រីគ្មានដីធ្វើស្រែចំការទេ ពេលទំនេរពីធ្វើកម្មករសំណង់ ប្តីរបស់បងស្រី បានទៅស៊ីឈ្នួលបាញ់ថ្នាំកសិកម្ម។ ប្តីគាត់តែងតែត្អូញត្អែរប្រាប់ថា ម្ចាស់ស្រែតំរូវឱ្យលាយថ្នាំពី ០៥ ទៅ ១០ ប្រភេទចូលគ្នា ថែមទាំងពុំមានផ្តល់ឧបករណ៍ការពារខ្លួនពេលដែលលាយថ្នាំពុលទាំងនោះឡើយ ឯចំណែកការបាញ់ថ្នាំវិញក៏មិនគិតពីពេលវេលាដែរ។ នៅពេលលាយថ្នាំម្តងៗ ក្លិនថ្នាំឈ្ងុលឡើងធ្វើឱ្យគាត់វិលមុខញ័រកញ្ជ្រាប់ និងពេលខ្លះដួលសន្លប់ដោយសារក្លិនថ្នាំកំពប់ប្រឡាក់ខ្លួននៅពេលបាញ់។ ក្នុងមួយថ្ងៃគាត់បាញ់ថ្នាំពី ១០ ទៅ ១៥ធុង។ បើគិតពីថ្ងៃចាប់ផ្តើមស៊ីឈ្នួលបាញ់ថ្នាំរហូតដល់ថ្ងៃស្លាប់គឺ មានរយៈពេលត្រឹមតែ០៣ខែប៉ុណ្ណោះ។ ប្រាក់កំរៃដែលទទួលពីការស៊ីឈ្នួលបាញ់ថ្នាំមិនអាចព្យាបាលជំងឺប្តីគាត់បានទេ។ បងស្រីមានបន្ទុកគ្រួសារធ្ងន់ធ្ងរណាស់គឺ ចិញ្ចឹមកូន០៣នាក់និងឪពុកម្តាយចាស់ជរា។ បងស្រីស៊ីឈ្នួលស្ទូងស្រូវបានកំរៃមួយថ្ងៃប្រហែល ៨,០០០ រៀល (ប្រាំបីពាន់រៀលគត់) ប៉ុន្តែត្រូវចំណាយថ្លៃម៉ូតូឌុប ៥,០០០ រៀល នៅសល់ ៣,០០០ រៀល ទុកសំរាប់ថ្លៃអាហារ និងចំណាយក្នុងគ្រួសារ។ ក្រោយពេលប្តីស្លាប់ទៅ បងស្រីមានការសោកស្តាយនូវទង្វើរបស់ប្តីដែលមិនបានគិតពិចារណា និងប្រុងប្រយ័ត្នទើបទទួលរងឥទ្ធិពលពីថ្នាំកសិកម្មរហូតដល់ស្លាប់។ ឥឡូវនេះបងស្រីមានជីវភាពរស់នៅយ៉ាងលំបាក ដោយប្រឈមមុខទៅនឹងការសងបំណុលគេ (ខ្ចីប្រាក់ដើម្បីព្យាបាលជំងឺប្តី) ជាពិសេសកូនៗមិនបានទៅសាលារៀន។

ទន្ទឹមគ្នានេះដែរបងស្រីបានមានសំណូមពរទៅរាជរដ្ឋាភិបាល ឱ្យបញ្ឈប់ការនាំចូលថ្នាំកសិកម្ម ព្រោះអាចជាមូលហេតុធ្វើឱ្យបាត់បង់សមាជិកគ្រួសារ និងស្ត្រីមេម៉ាយ។ ថ្នាំកសិកម្មបានសំលាប់ប្រជាជនក្រីក្រ និងជនដែលងាយនឹងរងគ្រោះអស់ជាច្រើននាក់កន្លងមកហើយ។

អត្ថបទដោយ លោកស្រី **ម៉ែន វណ្ណារី**

មន្ត្រីគំរោងកាត់បន្ថយថ្នាំកសិកម្ម និងកសិកម្មនិរន្តរភាព

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**